**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា

រាជធានីភ្នំពេញ ថ្ងៃទី.២៦.. ខែធ្នូ ឆ្នាំ២០១៤

# របាយការណ៍

## ស្ដីពីសកម្មភាព និងលទ្ធផលការងាររបស់វិទ្យាស្ថានប្រចាំឆ្នាំ២០១៤

## ចាប់ពីថ្ងៃទី០១ ខែមករា ដល់ថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៤

**សភាពការណ៍រួម**

អនុវត្តតាមតួនាទី និងភារកិច្ចរបស់ខ្លួន ជាពិសេសដើម្បីចូលរួមអនុវត្តផែនការយុទ្ធសាស្ត្ររបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្នុងការសម្រេចឲ្យបាននូវគោលនយោបាយចតុកោណដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាលកម្ពុជានាឆ្នាំ២០១៤នេះ វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជាបានបន្តការខិតខំប្រឹងប្រែងអនុវត្តយ៉ាងសស្រាក់សស្រាំលើការងារស្រាវជ្រាវ និងអភិវឌ្ឍន៍បច្ចេកវិទ្យាសម្រាប់ (១)ការអភិវឌ្ឍន៍ពូជដំណាំផ្សេងៗរួមមាន ស្រូវ ពោត សណ្ដែក ដំឡូងមី បន្លែ ឈើហូបផ្លែ ដំណាំលម្អ (២)ការគ្រប់គ្រងដីជាតិដី និងសារធាតុចិញ្ចឹម (៣)ការអភិវឌ្ឍន៍បច្ចេកទេសដាំដុះ និងប្រព័ន្ធកសិកម្ម (៤)ការការពារដំណាំពីការបំផ្លាញរបស់កត្តាចង្រៃផ្សេងៗមានដូចជាសត្វល្អិតចង្រៃស្មៅ និងជំងឺ (៥)ការអភិវឌ្ឍន៍បច្ចេកទេសមុន និងក្រោយពេលប្រមូលផល (៦)ការវិភាគសេដ្ឋកិច្ចសង្គមពាក់ព័ន្ធវិស័យកសិកម្ម និង(៧)ការបណ្ដុះបណ្ដាល ការផ្សព្វផ្សាយចំណេះដឹងបច្ចេកទេស និងព័ត៌មានកសិកម្ម។

បានទទួលគណៈប្រតិភូមកពីប្រទេសបង់ក្លាដេសចំនួន៦រូប ដែលដឹកនាំដោយ Mr. Md. Hemayet Uddin, Deputy Secretary នៃក្រសួងកសិកម្មប្រទេសបង់ក្លាដេស។

បានចូលរួមក្នុងពិធីបុណ្យអង្ករកម្ពុជាលើកទី២ និងចូលរួមក្នុងវេទិកាស្រូវអង្ករ ឆ្នាំ២០១៤ នៅសណ្ឋាគារសូហ្វីតែលភូគីត្រា និងមជ្ឈមណ្ឌលពិព័រណ៍ និងសន្និបាតកោះពេជ្រ រាជធានីភ្នំពេញ ដែលក្នុងនោះអង្ករផ្ការំដួល នៃពូជស្រូវផ្ការំដួល ដែលបញ្ចេញដោយវិទ្យាស្ថាន ទទួលបានជ័យលាភីលេខ ១ លើពិភពលោក ប្រចាំឆ្នាំ២០១៤ ដែលជាជ័យលាភី៣ឆ្នាំបន្តបន្ទាប់គ្នាចាប់តាំងពីឆ្នាំ២០១២-២០១៤។

បានប្រារព្ធពិធីអបអរសាទរទិវានារីអន្តរជាតិលើកទី១០៣ ក្រោមប្រធានបទ "សមភាពនៃការអប់រំមានសារៈសំខាន់ក្នុងការអភិវឌ្ឍន៍សង្គម" រៀបចំប្រារព្ធធ្វើពិធីសូត្រមន្តបុណ្យចូលឆ្នាំខ្មែរប្រពៃណីជាតិ ឆ្នាំមមី ឆស័ក ព.ស ២៥៥៨ ពិធីបុណ្យគម្រប់ខួប១៥ឆ្នាំរបស់វិទ្យាស្ថាន និងទិវាច្រូតស្រូវរបស់វិទ្យាស្ថាន។

## ១- ការងារគ្រប់គ្រង

### ១.១- ការងារថ្នាក់ដឹកនាំ

ថ្នាក់ដឹកនាំវិទ្យាស្ថានបានអញ្ជើញចូលរួមប្រជុំអចិន្ត្រៃយ៍ និងប្រជុំផ្សេងៗនៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទចំនួន៦៦លើក និងប្រជុំផ្សេងៗនៅក្នុងវិទ្យាស្ថានចំនួន៦០លើក និងស្ថាប័ន/អង្គភាពនានាចំនួន៦០លើក។ ទន្ទឹមនឹងនេះថ្នាក់ដឹកនាំវិទ្យាស្ថានបានចូលរួមប្រជុំ និងសិក្ខាសាលាផ្សេងៗចំនួន១៦លើកនៅប្រទេសថៃ នេប៉ាល់ ចិន ជប៉ុន អ៊ីតាលី អូស្ត្រាលី កូរ៉េ ឡាវ ហ្វីលីពីន និងវៀតណាម។

ថ្នាក់ដឹកនាំវិទ្យាស្ថានបានទទួលជួបបង្ហាញនូវលទ្ធផលការងារពិសោធន៍ស្រាវជ្រាវ និងពិភាក្សាជាមួយគណៈប្រតិភូ ភ្ញៀវជាតិ និងអន្តរជាតិចំនួន២០០នាក់។ ភ្ញៀវដែលថ្នាក់ដឹកនាំវិទ្យាស្ថានទទួលជួបមកពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងអង្គភាព/ស្ថាប័នក្នុងប្រទេសរួមមាន ព្រឹទ្ធសភា ក្រសួងធនធានទឹក និងឧតុនិយម ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងបរិស្ថាន វិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា, AGRO and TGCH Co. Ltd., Bayer, Cambodian Rice Factory, CAVAC, Coastal Adaptation CC, Forword (Cambodia) Co.,LTD, FTC, Hanwha, KOTRA, JIRCAS, LYS Sovannaphum Group, Pioneer Cambodia, Plant Strengthener, PPIC, SEARCA, TAN CONS Co.,Ltd និង USAID ព្រមទាំងអង្គភាពស្ថាប័ន ប្រទេសនានារួមមាន Agilent Technologies (Singapore), APEC Climate Center (Korea), Bayer (Vietnam), Bioversity International,

CN (Japan), Daiwa Lease Co., Ltd. (Japan), Eurofins (USA), FECC of Ministry of Agriculture (China), FRC/NAFRI (Lao PDR), Guangxi Forword Agriculture Technology International Cooperation Co.,Ltd (China), i-Corporation Co., Ltd. (Japan), ICCAE (Japan), Hirosaka University (Japan), Hokkaido University (Japan), Idemitsu (Japan), IFC, Koide University (Japan), KECC (Korea), Kyushu University (Japan), Locoma (Japan), Michigan State University (USA), Ministry of Agriculture (Bangladesh), Ministry of Fisheries and Livestock (Bangladesh), Ministry of Planning (Bangladesh), Nagoya University (Japan), National Institute of Genetics (Japan), NHK Television (Japan), NSWPPI (Australia), Pioneer (Thailand), RDA (Korea), Setra (Malaysia), Shinshu University (Japan), Super Map Software (China), Tan Machinery & Trading (China), Tasmanian Institute of Agriculture (Tasmania), UNEP Ri Se Center of DTU (Denmark), University of Bedfordshire (English) និង Yanmar (Japan)។

## ១.២- ការងាររដ្ឋបាល បុគ្គលិក

បានសម្របសម្រួលការងាររដ្ឋបាល ផ្គត់ផ្គង់សម្ភារ កសាងគម្រោងថវិកា គ្រប់គ្រងចរាចរឯកសារ ការងារពិធីការ ការងារសន្តិសុខ សំណុំបញ្ជាប់ អនាម័យ និងសរុបរបាយការណ៍ផ្សេងៗ។ ទន្ទឹមនឹងនេះក៏បានគ្រប់គ្រងការប្រើប្រាស់ប្រេងឥន្ធនៈ ការប្រើប្រាស់រថយន្ត ថែទាំ និងជួសជុលអគារ ព្រមទាំងដំណើរការការងារគ្រប់គ្រងបុគ្គលិក និងធនធានមនុស្ស។ចំពោះស្ថានភាពមន្ត្រី និយោជិតវិទ្យាស្ថានប្រចាំឆ្នាំ២០១៤ រួមមានដូចតារាងខាងក្រោមៈ

តារាងស្ថានភាពមន្ត្រីរាជការ បុគ្គលិកកិច្ចសន្យា និងពលករអណ្តែតនៃវិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា

| កម្រិតវប្បធម៌ | មន្ត្រីរាជការកំពុងបំពេញការងារ | មន្ត្រីរាជការបន្តការសិក្សា | មន្ត្រីរាជការព្យួរការងារ | មន្ត្រីរាជការកម្មសិក្សា | បុគ្គលិកកិច្ចសន្យារយៈពេលវែង | ពលករអណ្តែត | សរុប |
|---|---|---|---|---|---|---|---|
| ថ្នាក់បណ្ឌិត | ៥ | - | - | - | - | - | ៥ |
| ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ | ១៤ | ២ | - | - | - | - | ១៦ |
| ថ្នាក់បរិញ្ញាបត្រ | ១៥ | - | - | ៨ | ៨ | - | ៣១ |
| ថ្នាក់បរិញ្ញាបត្ររង | - | - | - | - | - | - | - |
| កម្រិតវប្បធម៌ទូទៅ | ៨ | - | - | - | - | ១០០ | ១០៨ |
| សរុប | ៤២ | ២ | - | ៨ | ៨ | ១០០ | ១៦០ |

មន្ត្រីរាជការសរុបចំនួន៥១នាក់ ក្នុងនោះនារីចំនួន១១នាក់។

## ១.៣- ការងារគណនេយ្យ ហិរញ្ញវត្ថុ

បានគ្រប់គ្រងចលនាសាច់ប្រាក់ និងទូទាត់ប្រាក់ចំណូល-ចំណាយ តាមដានអត្រាប្តូរប្រាក់ រៀបចំ និងបើកផ្តល់ កម្រៃប្រាក់ឈ្នួល ប្រាក់ឧបត្ថម្ភ និងប្រាក់បៀវត្ស ព្រមទាំងតាមដាន ផ្ទៀងផ្ទាត់ឯកសារសក្ខីប័ត្របេឡា ធនាគារ រតនាគារជាតិ ធ្វើរបាយការណ៍ផ្គូផ្គងប្រចាំខែ និងរៀបចំកត់ត្រាបញ្ជីកាបេឡា គណនេយ្យ។

បានកត់ត្រា ត្រួតពិនិត្យ និងតាមដានសំណើសុំថវិកា គ្រប់គ្រងប្រភពចំណូលថវិកា តាមដាន និងត្រួតពិនិត្យការជម្រះបញ្ជីថវិកាបុរេប្រទាន ការទូទាត់ចំណាយបេឡា រៀបចំចងក្រងឯកសារហិរញ្ញប្បទាន និងធ្វើរបាយការណ៍សមតុល្យហិរញ្ញវត្ថុ។

បានត្រួតពិនិត្យឯកសារសំណើទិញ ស្រង់តម្លៃ រៀបចំឯកសារបញ្ជាទិញ និងផ្គត់ផ្គង់ សម្របសម្រួលដំណើរពិគ្រោះថ្លៃ និងដេញថ្លៃ គ្រប់គ្រងសន្និធិប្រេងឥន្ធនៈ ជីគីមី គ្រាប់ពូជដំណាំ និងកសិផល គ្រប់គ្រងចលនទ្រព្យ អចលនទ្រព្យសន្និធិសម្ភារ ធ្វើបញ្ជីសារពើភ័ណ្ឌ និងរៀបចំចងក្រងឯកសារផ្គត់ផ្គង់សន្និធិ និងឯកសារពាក់ព័ន្ធ។

## ១.៤- ការងារផែនការ សហប្រតិបត្តិការ និងពាណិជ្ជកម្ម

បានតាមដានវឌ្ឍនភាពនៃការអនុវត្តន៍គម្រោងស្រាវជ្រាវ និងអភិវឌ្ឍន៍បច្ចេកវិទ្យា។ ធ្វើការត្រួតពិនិត្យតាមដានរាល់វឌ្ឍនភាពនៃការដាក់ស្នើសុំគម្រោងនានាជាមួយដៃគូអភិវឌ្ឍន៍។ បានរៀបចំផែនការសកម្មភាពថវិកាតាមទម្រង់ P3 និង P4 ឲ្យស្របតាមតួលេខថវិកាដែលបានបែងចែក។

បានតាមដានវឌ្ឍនភាពនៃការរៀបចំគោលការណ៍ចំណាយប្រចាំឆ្នាំ និងឆមាស ឆ្នាំ២០១៤ របស់ការិយាល័យមជ្ឈមណ្ឌលក្រោមឱវាទវិទ្យាស្ថាន ក្នុងការអនុវត្តគម្រោងស្រាវជ្រាវមួយចំនួនក្រោយពីទទួលបានការផ្តល់ហិរញ្ញប្បទានថវិការាជរដ្ឋាភិបាលនាឆ្នាំ២០១៤។

បានអភិវឌ្ឍន៍ផែនការយុទ្ធសាស្ត្ររបស់វិទ្យាស្ថានពីឆ្នាំ២០១៥ដល់២០១៧អំពីការស្រាវជ្រាវ អភិវឌ្ឍន៍បច្ចេកវិទ្យាកសិកម្ម និងថវិកាដើម្បីដាក់ជូនក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

បានអភិវឌ្ឍន៍ផែនការស្រាវជ្រាវ អភិវឌ្ឍន៍បច្ចេកវិទ្យាកសិកម្ម និងថវិកាប្រចាំឆ្នាំ២០១៥ ទៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដែលមានទំហំថវិកាសរុបចំនួន៣.៨៥៧,២លានរៀល ដែលក្នុងនោះថវិកាជំពូក៦៤មានចំនួន៦៥០,២លានរៀល និងថវិកាជំពូក៦៥០៣មានចំនួន៣.២០៧លានរៀល។

## ១.៥- ការងារគ្រប់គ្រងស្ថានីយ៍

បានបន្តថែទាំ និងកសាងហេដ្ឋារចនាសម្ព័ន្ធវិទ្យាស្ថាន សម្រួលក្នុងការអនុវត្តន៍ការងារពិសោធន៍ស្រាវជ្រាវក្នុងវិទ្យាស្ថាន និងធ្វើផលិតកម្មពូជស្រូវ ព្រមទាំងថែរក្សា និងជួសជុលឧបករណ៍គ្រឿងយន្តកសិកម្មរបស់វិទ្យាស្ថាន។

បានបន្តរៀបចំថែរក្សាហេដ្ឋារចនាសម្ព័ន្ធ អនុវត្តការងារពិសោធន៍ និងផលិតកម្មនៅស្ថានីយ៍ស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកោះកេរ្តិ៍ ខេត្តព្រះវិហារ។

បានធ្វើផលិតកម្មគ្រាប់ពូជសុទ្ធគ្រឹះ គ្រាប់ពូជសុទ្ធអនុញ្ញាត និងគ្រាប់ពូជសុទ្ធល្អ របស់ពូជស្រូវស្រាលចំនួន៣ពូជ ដែលក្រសួងបាន និងកំពុងជំរុញឲ្យកសិករដាំដុះបានចំនួន២១,៥ហិកតា បានផលប្រមាណ៥២,៨តោន។

# ២- សមិទ្ធផលការងារស្រាវជ្រាវ ការបណ្តុះបណ្តាល និងផ្សព្វផ្សាយ

ក្នុងឆ្នាំ២០១៤នេះ វិទ្យាស្ថានបានធ្វើពិសោធន៍ចំនួន៨០ប្រភេទ នៅ៧០៦កន្លែង ដែលនៅក្នុងនោះមានពិសោធន៍បន្សាំពូជលើស្រែកសិករ និងស្រែបង្ហាញចំនួន៥៥៩កន្លែង។ បានធ្វើអង្កេតចំនួន១១ប្រភេទលើកសិករចំនួន២.៥០០នាក់។ បានធ្វើការបែងចែកព្រឹត្តិបត្រព័ត៌មានកសិករចំនួន១០.១៣៣ច្បាប់ សៀវភៅរបាយការណ៍ប្រចាំឆ្នាំរបស់វិទ្យាស្ថានចំនួន៧២ច្បាប់ សៀវភៅទស្សនាវដ្តីកសិកម្មចំនួន១២១ច្បាប់ សៀវភៅកម្រងឯកសារក្សេត្របរិស្ថានដំណាំស្រូវក្នុងប្រទេសកម្ពុជា ការកំណត់ក្រុមដីស្រែលក្ខណៈសំខាន់ៗរបស់ពូជស្រូវចំនួន១០ពូជចំនួន៩៥១ក្បាល សៀវភៅបង្ហាញបច្ចេកទេសចំនួន៤១១ច្បាប់ ជូនអង្គភាពក្រោមឱវាទក្រសួង មន្ទីរកសិកម្មរាជធានី ខេត្ត ការិយាល័យកសិកម្មស្រុក និងអ្នកពាក់ព័ន្ធ ជាពិសេសដល់កសិករ។ សមិទ្ធផលការងារស្រាវជ្រាវរបស់វិទ្យាស្ថានចែកចេញជា៥ផ្នែកធំៗ ដែលសរុបទាំងអស់មានចំនួន៣៦ចំណុចដូចខាងក្រោមៈ

## ២.១-ការងារអភិរក្ស និងសម្ពាហកម្ម

**១- ពូជដំណាំ:** បន្តការអភិរក្សពូជដំណាំ ដែលមានក្នុងធនាគារពន្ធុ នៅក្នុងផ្ទះសំណាញ់ និងនៅក្នុងចម្ការ។ ទន្ទឹមនឹងនេះដែរបានធ្វើយុវកម្មលើដំណាំចំនួន២ប្រភេទ រួមមានស្រូវចំនួន៣៦៣បញ្ជីក/សំណាក និងដំឡូងមីចំនួន២៨សំណាក។ បានដាំស្រូវសម្រាប់ធ្វើការវាយតម្លៃ និងកំណត់លក្ខណៈចំនួន៦៩សំណាក ព្រមទាំងបានចុះប្រមូលបន្ថែម រៀបចំសម្អាត សម្ងួត និងវេចខ្ចប់ទុកដាក់សំណាកដំណាំបានចំនួន៦ប្រភេទ ដែលក្នុងនោះមានស្រូវចំនួន៦៦១សំណាក (ស្រូវប្រពៃណី និងកូនបង្កាត់ចំនួន៤៧២សំណាក ស្រទាយស្រូវនាំចូលចំនួន១៨៩សំណាក) អំពៅចំនួន៣សំណាក ល្ងចំនួន២សំណាក ដំឡូងជ្វាចំនួន២៣សំណាក សណ្តែកបាយចំនួន១សំណាក និងសណ្តែកដីចំនួន៤សំណាក សរុបមានចំនួន៦៩៤សំណាក។ គិតជារួមនៅក្នុងរយៈពេលមួយឆ្នាំ២០១៤នេះ វិទ្យាស្ថានបានប្រមូល និងបន្តអភិរក្សលើដំណាំចំនួន៣០ប្រភេទ ដែលក្នុងនោះមានស្រូវចំនួន៦.៦២១បញ្ជីក/សំណាក និងដំណាំផ្សេងចំនួន២៩ប្រភេទរួមមាន៩៩៨បញ្ជីក/សំណាក សរុបទាំងអស់មានចំនួន៧.៦១៩បញ្ជីក/សំណាក។

**២- សម្ពាហកម្មសត្វល្អិតៈ** បានធ្វើការប្រមូលសត្វល្អិតលើដំណាំស្រូវចំនួន៤ប្រភេទ (មមាចខ្មោត ដង្កូវម្ជុរស្លឹក កណ្តូបអង់តែនខ្លី និងសង្កើចខ្មៅ) និងស្វាយចំនួន៣ប្រភេទ (រុយចោះផ្លែ ស្កែលស្វាយ និងក្រាស្វាយ)។

## ២.២- ការអភិវឌ្ឍន៍ និងជ្រើសរើសពូជដំណាំ

**៣- ពូជស្រូវដំណើបស្បៃមង្គលៈ** វិទ្យាស្ថានបានបញ្ចេញពូជស្រូវដំណើបស្បៃមង្គល ដែលជាពូជស្រូវដំណើបដំបូង និងជាពូជស្រូវទី៣៩ របស់វិទ្យាស្ថាន ជូនកសិករប្រើប្រាស់។ ដំណើបស្បៃមង្គល ជាពូជស្រូវធ្ងន់ប្រកាន់រដូវចេញផ្កាក្នុងសប្តាហ៍ទី២ ខែវិច្ឆិកា មានទិន្នផលជាមធ្យម៣,២តោន/ហិកតា កម្ពស់ជាមធ្យម១,៥ម៉ែត្រ ប្រវែងកួរជាមធ្យម២៩

សង់ទីម៉ែត្រ និងគ្រាប់ស្រូវ១០០គ្រាប់មានទម្ងន់៣,៤ក្រាម។ អង្ករលូនវែងមានប្រវែងគ្រាប់៧មីលីម៉ែត្រ បន្ទារកម្រាស់២,១មីលីម៉ែត្រ និងមានកម្រិតអាមីឡូស១,៦%។ ទន្ទឹមនឹងនោះ បានបែងចែកពូជស្រូវនេះដល់មន្ទីរកសិកម្មទាំងអស់ចំនួន១០គ.ក្រ/មន្ទីរ និងនាយកដ្ឋានដំណាំស្រូវ ដើម្បីពង្រីកពូជទុកផ្សព្វផ្សាយជូនដល់កសិករ។

**៤- ការងារបសិដ្ឋកម្មពូជស្រូវ:** បានដាំស្រទ្បាយស្រូវសម្រាប់ធ្វើការបង្កាត់ត្រឡប់ និងដាំបង្កើនជំនាន់ចំនួន១ប្រជាករ និងដាំតាមដានលើការលូតលាស់របស់ស្រទ្បាយបង្កាត់ដើម្បីអភិវឌ្ឍពូជស្រូវឲ្យមានភាពធន់ទ្រាំនឹងរាំងស្ងួត ធន់ទ្រាំនឹងអាកាសធាតុក្តៅ ធន់ទ្រាំនឹងជំងឺ អភិវឌ្ឍពូជលើទិន្នផល គុណភាពគ្រាប់ ធន់ទ្រាំនឹងជាតិប្រៃ តំណពូជនៃលក្ខណៈគុណភាពអង្ករ (SNP) ធន់ទ្រាំនឹងការដួលដើម និងជម្រើសឯកត្តៈពូជស្រូវស្នាច់ចំនួន១០ប្រភេទពិសោធន៍ ដែលមានសរុបចំនួន៤.៥៤៨ស្រទ្បាយ។

**៥- ពិសោធន៍ជ្រើសរើសពូជដំណាំ:** ចំពោះការងារពិសោធន៍ជ្រើសរើសរកពូជដំណាំថ្មី (ស្រូវ ពោត សណ្តែកបាយ សណ្តែកសៀង ល្ង ប៉េងប៉ោះ ម្ទេស ឪឡឹក ស្វាយ និងដំឡូងជ្វា) ប្រកបដោយសក្តានុពលទិន្នផល និងគុណភាពល្អ សរុបមានពិសោធន៍ចំនួន៤៨ប្រភេទ ក្នុងនោះពិសោធន៍គ្មានសារ និងពិសោធន៍មានសារសរុបចំនួន៧៥ពិសោធន៍ ពិសោធន៍បន្សាំពូជបឋមលើស្រែកសិករចំនួន១២៥ពិសោធន៍ និងស្រែបង្ហាញមានចំនួន៨២ ដែលមានពូជ/ស្រទ្បាយចូលរួមសរុបចំនួន១.១៨១ពូជ/ស្រទ្បាយ។

**៦- ផលិតកម្មគ្រាប់ពូជដំណាំ:** ដើម្បីធានានូវភាពសុទ្ធ និងគុណភាពគ្រាប់ពូជដំណាំដែលបានបញ្ជាញឲ្យកសិករប្រើប្រាស់កន្លងមក វិទ្យាស្ថានបានធ្វើផលិតកម្មគ្រាប់ពូជដំណាំចំនួន៦ប្រភេទ ដែលក្នុងនោះមានស្រទ្បាយស្រូវចំនួន២០ពូជ សណ្តែកបាយចំនួន៤ពូជ ពោតចំនួន២ពូជ ប៉េងប៉ោះចំនួន២ពូជ ឪឡឹកចំនួន២ពូជ និងស្វាយចំនួន២ពូជ សរុបចំនួន៣២ពូជដំណាំ។

**៧- ការដាំពង្រីកគ្រាប់ពូជ/ស្រទ្បាយដំណាំ:** ជាមួយគ្នានោះដែរដើម្បីធានានូវបរិមាណគ្រាប់ពូជដំណាំសម្រាប់ការងារពិសោធន៍ស្រាវជ្រាវ វិទ្យាស្ថានបានដាំពង្រីកស្រទ្បាយពូជដំណាំចំនួន៥ប្រភេទ ដែលក្នុងនោះមាន ស្រទ្បាយស្រូវស្រាលចំនួន៤៨ស្រទ្បាយ ស្រទ្បាយស្រូវធន់ទ្រាំនឹងទឹកជំនន់ចំនួន៦៤ស្រទ្បាយ ស្រទ្បាយស្រូវធន់ទ្រាំនឹងកម្តៅចំនួន៤១ស្រទ្បាយ ស្រទ្បាយស្រូវកណ្តាលចំនួន៣៧ស្រទ្បាយ ឪឡឹកចំនួន១ស្រទ្បាយ ប៉េងប៉ោះចំនួន៧ស្រទ្បាយ ម្ទេសប្លោកចំនួន១១ស្រទ្បាយ សណ្តែកដីចំនួន១២ស្រទ្បាយ និងសណ្តែកសៀងចំនួន១០ស្រទ្បាយ សរុបចំនួន២៣១ស្រទ្បាយ។

## ២.៣- ការបង្កើនផលិតភាពដំណាំ

**៨- ការវាយតម្លៃផលិតភាពដំណាំស្រូវក្នុងរដូវប្រាំង:** លទ្ធផលនៃការពិសោធន៍បានធ្វើឡើងចំនួន១ពិសោធន៍ ដែលបានដាំដុះនៅលើក្រុមដីប្រទះឡាងក្នុងវិទ្យាស្ថានបានបង្ហាញថា ការប្រើប្រាស់ជីតាមកម្រិតណែនាំរបស់វិទ្យាស្ថានបានបង្កើនទិន្នផលប្រមាណ៤៣% ធៀបជាមួយការមិនប្រើប្រាស់ជី ដែលធ្វើឲ្យទិន្នផលទទួលបាន៤តោន/ហិកតា។ ការបង្កើនការប្រើប្រាស់ជីអាសូតកន្លះកម្រិតបន្ថែមពីលើកម្រិតណែនាំ ពុំបានបង្កើនទិន្នផលស្រូវឡើយចំពោះពូជស្រូវកណ្តាលផ្ការំដួល។ ទិន្នន័យអំពីដី និងអាកាសធាតុត្រូវបានប្រមូលកត់ត្រា ដើម្បីប្រើប្រាស់ក្នុងប្រព័ន្ធគម្រូផលិតកម្មសម្រាប់ព្យាករណ៍ស្ថានភាពផលិតកម្មស្រូវក្នុងពេលអនាគត។




ក្រាហ្វិក១. ទិន្នផលស្រូវផលសារដែលបានពីការប្រើប្រាស់ជីក្នុងកម្រិតផ្សេងៗគ្នាលើក្រុមដីប្រទះឡាងក្នុងវិទ្យាស្ថាន

ចំពោះស្រែបង្ហាញចំនួន៣កន្លែងទៀត ដែលបានធ្វើនៅលើក្រុមដីប្រទះឡាង ក្នុងស្រុកគងពិសី ខេត្តកំពង់ស្ពឺ បានបង្ហាញថា ទិន្នផលស្រូវមានការប្រែប្រួលពីស្រែកសិករមួយទៅស្រែកសិករមួយ ប៉ុន្តែជាទូទៅការប្រើប្រាស់ជីតាមកម្រិតណែនាំ ទទួលបានទិន្នផលខ្ពស់ជាងទិន្នផលដែលបានពីការប្រើប្រាស់ជីតាមទម្លាប់កសិករ។ ការប្រើប្រាស់ជីតាមទម្លាប់កសិករជាទូទៅទទួលបានទិន្នផលមធ្យម២,៧តោន/ហិកតា តែការប្រើប្រាស់ជីតាមកម្រិតណែនាំទទួលបានទិន្នផលជាមធ្យម៤,៥តោន/ហិកតា។

តារាង១. ទិន្នផលស្រូវមធ្យមដែលបានពីការធ្វើពិសោធន៍ស្រែបង្ហាញចំនួន៣លើក្រុមដីប្រទះឡាង ក្នុងស្រុកគងពិសី

| បច្ច័យប្រើជី (គ.ក្រ/ហាត) | ទិន្នផល (តោន/ហាត), រដូវប្រាំង ឆ្នាំ២០១៤ | | | មធ្យម | ចំណេញដុល |
|---|---|---|---|---|---|
| | ស្រែបង្ហាញទី១ | ស្រែបង្ហាញទី២ | ស្រែបង្ហាញទី៣ | | (លានរៀល) |
| 100-40-80 (N-$P_2O_5$-$K_2O$) | 5.18 | 4.37 | 3.95 | 4.50 | 2.70 |
| 150-40-80 (N-$P_2O_5$-K2O) | 5.28 | 4.32 | 2.45 | 4.02 | 2.09 |
| Farmer Fertilizer Practice | 4.00 | 3.03 | 1.05 | 2.69 | 1.72 |
| *Treatment mean (n=3)* | *4.82* | *3.9* | *2.49* | | |

លទ្ធផលនៃការវាយតម្លៃតាមរយៈទិន្នផលជាក់ស្តែង និងវិភាគសេដ្ឋកិច្ចលើស្រែបង្ហាញទាំងបីបានបង្ហាញថាការប្រើប្រាស់ជីតាមកម្រិតណែនាំរបស់វិទ្យាស្ថានទទួលបានទិន្នផលខ្ពស់ជាងគេ និងទទួលបានប្រាក់ចំណេញដុលប្រមាណ២,៧លានរៀល/ហិកតា។ ឯការប្រើប្រាស់ជីតាមទម្លាប់កសិករទទួលបានទិន្នផលទាប និងប្រាក់ចំណេញដុលប្រមាណ១,៧លានរៀល/ហិកតា។

**៩- ការប្រើប្រាស់ និងគុណភាពទឹកក្រោមដីសម្រាប់ផលិតកម្មដំណាំ:** ការសិក្សានេះធ្វើឡើងក្នុងគោលបំណង ដើម្បីតាមដានអំពីគុណភាពទឹកក្រោមដីសម្រាប់ផលិតកម្មដំណាំស្រូវ។ សំណាកទឹកមួយចំនួនត្រូវបានធ្វើការតាមដានរយៈពេលវែង នៅតំបន់ដែលមានការប្រើប្រាស់ទឹកក្រោមដីច្រើន ជាពិសេសនៅភូមិទួលសាំងក និងភូមិតាអី ក្នុងស្រុកអង្គរបុរី ខេត្តតាកែវ ដោយបានវិភាគលើប៉ារ៉ាម៉ែត្រសំខាន់ៗដូចជា ប៉េហាស់ (pH) ភាពចម្លងអគ្គីសនី (EC) ជាតិអាល់កាឡាំង ($CaCO_3$) ជាតិដែក (Fe) នីត្រាត ($NO_3^-$) និងភាពកករ (Turbidity)។ ជាលទ្ធផល pH មានតម្លៃជុំវិញណឺត ដែលអនុគ្រោះដល់ការដុះលូតលាស់របស់ដំណាំ។ ប៉ារ៉ាម៉ែត្រមួយចំនួនទៀតដូចជា ដែក អាលុយមីញ៉ូម នីត្រាត និងភាពកករ ពុំបានបង្ហាញឲ្យឃើញពីកម្រិតដែលនាំឲ្យប៉ះពាល់ដល់ដំណាំឡើយ។ ជាទូទៅកំហាប់អំបិលមានកម្រិតខ្ពស់ ដែលនាំឲ្យមានផលប៉ះពាល់ដល់ការដុះលូតលាស់ និងទិន្នផលដំណាំ។ តាមការសង្កេតរបស់កសិករបង្ហាញថា ការប្រើប្រាស់ទឹកក្រោមដីទាំងស្រុងពេញមួយដំណាំដោយពុំមានទឹកភ្លៀង ឬទឹកផ្ទៃលើស្រោចស្រពជាមួយជាពិសេសការដាំដំណាំនៅរដូវប្រាំងនាំឲ្យទិន្នផលដំណាំមានការធ្លាក់ចុះគួរឲ្យកត់សម្គាល់។

តារាង២. លទ្ធផលនៃការវិភាគលើប៉ារ៉ាម៉ែត្រសំខាន់ៗមួយចំនួនលើសំណាកទឹកអណ្តូង (ឆ្នាំ២០១៤)ក្នុងស្រុកអង្គរបុរី ខេត្តតាកែវ

| ទីកន្លែង | pH | EC mS/cm | Fe(LR) mg/l | Al mg/l | $NH_4^+$ mg/l | Ca mg/l | អាល់កាឡាំង mg/l | ភាពកករ NTU |
|---|---|---|---|---|---|---|---|---|
| ភូមិទួលសាំងគ | 6.9 | 1.5 | 0.0 | 0.0 | low | 52.3 | 268.5 | 10.6 |
| ភូមិតាអី | 7.1 | 1.9 | 0.0 | 0.0 | low | 55.7 | 217.5 | 10.4 |

**១០- ឥទ្ធិពលនៃរបបទឹកស្រោចស្រព និងកម្រិតអាសូតទៅលើការដុះលូតលាស់និងទិន្នផលស្រូវស្រាលលើក្រុមដីប្រទះឡាង:** ការសិក្សានេះបានអនុវត្តក្នុងវិទ្យាស្ថានកាឌី លើក្រុមដីប្រទះឡាង ជាលទ្ធផលបានបង្ហាញថា ការបង្កើនកម្រិតអាសូតមួយកម្រិតកន្លះណែនាំសម្រាប់ក្រុមដីប្រទះឡាងមិនបានជួយដល់ការលូតលាស់ និងទិន្នផលស្រូវស្រាលនោះទេ ដោយទិន្នផលស្រូវជាមធ្យមប្រែប្រួលពី២,៨៥-២,៨៦តោន/ហិកតា។ ដោយឡែកកត្តានៃរបបទឹកស្រោចស្រពបានកំណត់ឥទ្ធិពលទៅលើការដុះលូតលាស់ និងទិន្នផលស្រូវ ហើយការពន្លិចទឹកជាប់ទទួលបានទិន្នផលខ្ពស់ជាងគេជាមធ្យម៣,៥៨តោន/ហិកតា ដោយបានប្រើប្រាស់ទឹកក្នុងបរិមាណ៦.៧៦០ម៉ែត្រគូប/ហិកតា បន្ទាប់មកគឺការកំណត់

ពេលវេលាក្នុងការស្រោចស្រព (ដក់ទឹក១៥ថ្ងៃ និងមិនដក់ទឹក១៥ថ្ងៃ) ទទួលបានទិន្នផលជាមធ្យម២,៩តោន/ហិកតា ដោយបានប្រើប្រាស់ទឹកអស់បរិមាណ៣.៩៧០ម៉ែត្រគូប/ហិកតា។ ចំណែកឯការស្រោចស្រពត្រឹមកម្រិតឲ្យដីសើមគឺទទួលបានទិន្នផលទាបជាងគេ ដែលជាមធ្យម២តោន/ហិកតា ដោយបានប្រើប្រាស់ទឹកអស់បរិមាណ២.៧៤០ម៉ែត្រគូប/ហិកតា។




ក្រាហ្វិក២. ទិន្នផលមធ្យមនៃរបបទឹកស្រោចស្រពផ្សេងគ្នាទៅនឹងកម្រិតអាសូតលើក្រុមដីប្រទះឡាង

**១១- ប្រសិទ្ធភាពនៃរបបទឹក និងកម្រិតជីអាសូតទៅលើការដុះលូតលាស់ និងទិន្នផលស្រូវលើក្រុមដីប្រទះឡាង នៅក្នុងលក្ខខណ្ឌផ្ទះកញ្ចក់:** ការសិក្សានេះបានធ្វើឡើងនៅក្នុងលក្ខខណ្ឌផ្ទះកញ្ចក់នៃវិទ្យាស្ថានកាឌី លើក្រុមដីប្រទះឡាង ជាលទ្ធផលដែលបានពីការធ្វើពិសោធន៍បានបង្ហាញថា ការស្រោចស្រពតាមវិធីសាស្ត្រសមត្ថភាពចាប់យកទឹករបស់ដីស្រែ (FC) ពុំបានបង្កើនប្រសិទ្ធភាពការប្រើប្រាស់ជីឡើយ ទោះបីកម្រិតជីអាសូតត្រូវបានបង្កើនរហូតដល់បរិមាណ១៥០គីឡូក្រាម/ហិកតាក៏ដោយ។ ចំពោះការស្រោចស្រពក្នុងកម្រិតដីឆ្អែតទឹក (SD) បានបង្កើនប្រសិទ្ធភាពការប្រើប្រាស់ជីគួរឲ្យកត់សម្គាល់បើកម្រិតអាសូត ត្រូវបានបង្កើនរហូតដល់ ១០០គីឡូក្រាម/ហិកតា ដោយទិន្នផលទទួលបានប្រមាណ១៤,៧៩ក្រាម/គុម្ព។ ប៉ុន្តែការបង្កើនកម្រិតអាសូតរហូតដល់១៥០គីឡូក្រាម/ហិកតា មិនបានបង្កើននូវប្រសិទ្ធភាពនៃការប្រើប្រាស់ជីឡើយ ដោយទិន្នផលទទួលបានប្រមាណ១៤,១៤ក្រាម/១គុម្ព។ ដោយឡែកការស្រោចស្រពតាមលក្ខខណ្ឌដីដាក់ទឹក៥សង់ទីម៉ែត្រជាប់ជាប្រចាំ (FD) បានជួយជំរុញឲ្យការប្រើប្រាស់ ជីអាសូតប្រកបដោយប្រសិទ្ធភាព ហើយទិន្នផលមានការកើនឡើងចន្លោះពី១២,៥២ក្រាម/គុម្ព (មិនដាក់ជី) រហូតដល់២៣,០៩ក្រាម/គុម្ព បើជីអាសូតត្រូវបានបង្កើនរហូតដល់១៥០គីឡូក្រាម/ហិកតា។




ក្រាហ្វិក៣. ទិន្នផលមធ្យម ក្រាម/គុម្ព នៃរបបទឹកស្រោចស្រពផ្សេងគ្នាទៅនឹងកម្រិតជីអាសូត លើក្រុមដីប្រទះឡាង

**១២. ការប្រើប្រាស់ទឹកដោយដំណាំស្រូវ:** លទ្ធផលនៃការតាមដាន និងពិសោធន៍រយៈពេល២–៥ឆ្នាំកន្លងមកបង្ហាញថា (១)រំហួតបរិយាកាស (Pan evaporation) មានជាមធ្យម៥ម.ម/ថ្ងៃ ក្នុងនោះទាបបំផុតក្នុងខែធ្នូមាន៤ម.ម/ថ្ងៃ

និងខ្ពស់បំផុតក្នុងខែមីនាមាន៦ម.ម/ថ្ងៃ ហើយមធ្យមរដូវប្រាំងមាន៥,០៥ម.ម/ថ្ងៃ និងរដូវវស្សាមាន៤,៩១ម.ម/ថ្ងៃ (២)ក្នុងដំណាំស្រូវរដូវប្រាំង មានរំហួតពីផ្ទៃទឹក (Evaporation) ជាមធ្យម៤,១ម.ម/ថ្ងៃ និងដោយដំណកដង្ហើម (Transpiration) ១,៦ម.ម/ថ្ងៃ និង(៣)ក្នុងដំណាំស្រូវរដូវវស្សាមានរំហួតពីផ្ទៃទឹកជាមធ្យម៣,៧ម.ម/ថ្ងៃ និងដោយដំណកដង្ហើម១,៤ម.ម/ថ្ងៃ។




ក្រាហ្វិក៤. រំហួតបរិយាកាស (Pan evaporation) និងរំហួតពីផ្ទៃទឹក (Evaporation) ព្រមទាំងរំហួតដោយដំណកដង្ហើម (Transpiration) របស់ដំណាំស្រូវក្នុងរដូវប្រាំង និងវស្សាក្នុងមួយថ្ងៃ

១៣. ប្រព័ន្ធដាំដុះដំណាំស្រូវលើដីប្រទះឡាងក្នុងតំបន់ស្រោចស្រពពេញលេញៈ លទ្ធផលពិសោធន៍រយៈពេល៣ឆ្នាំលើដីប្រទះឡាងបានបង្ហាញថា ជាមធ្យមក្នុងមួយឆ្នាំ (១)កសិករអាចដាំដុះដំណាំស្រូវបាន៣ដង ដោយប្រើពូជស្រូវជលសារ (ឬពូជស្រូវមានអាយុកាលខ្លីជាង១០០ថ្ងៃ) សម្រាប់ស្រូវប្រាំង (DS) និងស្រូវដើមរដូវវស្សា (EWS) និងពូជស្រូវផ្ការំដួល (ឬពូជស្រូវក្រអូបចេញផ្កាដំណាល) សម្រាប់រដូវវស្សា (WS) (២)ការដាំដុះដំណាំស្រូវ២ឬ៣ដងក្នុង១ឆ្នាំ ដោយការប្រើប្រាស់ដី និងរៀបចំដីសមស្របមិនបណ្ដាលឲ្យផលិតភាពដីធ្លាក់ចុះទេ (៣)ការដាំដុះដំណាំស្រូវ៣ដង/ឆ្នាំ (DS+EWS+WS) បង្កើនបរិមាណផលស្រូវក្នុងផ្ទៃដី១ហិកតាដល់១១,៨តោន និងប្រាក់ចំណេញសុទ្ធ១.៣៤០ដុល្លារ និង(៤)ការដាំដុះដំណាំស្រូវដើមរដូវវស្សា និងរដូវវស្សា (EWS+WS) ផ្ដល់បរិមាណផល៧,៧តោន និងប្រាក់ចំណេញសុទ្ធ១,០៧០ដុល្លារ ហើយក៏ជាប្រព័ន្ធដាំដុះដែលមានអត្រាវិនិយោគល្អជាងប្រព័ន្ធដាំដុះដទៃទៀត ព្រមទាំងអនុញ្ញាតិឲ្យកសិករអាចដាំដុះដំណាំបន្លែ ឬសណ្ដែកបាយក្នុងរដូវប្រាំង (ក្រាហ្វិក៥)។




ក្រាហ្វិក៥. បរិមាណផលស្រូវមធ្យម៣ឆ្នាំ (PY) ទុនចំណាយ (Input) ប្រាក់ចំណូល (Income) និងប្រាក់ចំណេញសុទ្ធ (GM) របស់ប្រព័ន្ធដាំដុះ ១)ស្រូវប្រាំង+ដើមរដូវវស្សា (DS+EWS) ២)ស្រូវប្រាំង+ស្រូវវស្សា (DS+WS) ៣)ស្រូវដើមរដូវវស្សា+ស្រូវវស្សា (EWS+WS) និង៤)ស្រូវប្រាំង+ស្រូវដើមរដូវវស្សា+ស្រូវវស្សា (DS+EWS+WS)

១៤. **ការបាត់បង់ផលស្រូវនាពេលច្រូតកាត់:** លទ្ធផលនៃការធ្វើពិសោធន៍ផ្ទាល់នៅលើស្រែកសិករចំនួន១៦កន្លងមក បានបង្ហាញថា ការច្រូតស្រូវដោយម៉ាស៊ីនកុំបៃ ផលស្រូវបាត់បង់តិចជាងគេ គឺជាមធ្យម៥% សមាមាត្រនឹងបរិមាណស្រូវប្រមាណ២១០គ.ក្រក្នុងមួយហិកតាចំណែកឯការច្រូតដោយដៃមានជាមធ្យម២,៤% ស្មើនឹងផលស្រូវ១០២គ.ក្រ ហើយការច្រូតដោយម៉ាស៊ីនកាត់ផ្តេក បាត់ជាមធ្យម៥,៤% ស្មើនឹងផលស្រូវ២៣០គ.ក្រ។




ក្រាហ្វិក៦. បរិមាណភាគរយផលស្រូវជ្រុះបាត់ដោយការច្រូតដោយដៃ (Mannual) ការច្រូតដោយម៉ាស៊ីនកាត់ផ្តេក (Ripper) និងច្រូតដោយម៉ាស៊ីនកុំបៃ (Combined).

១៥. **ការកម្ចាត់ខ្យងពំណាមាសឬខ្យងស៊ីស្រូវ:** លទ្ធផលពិសោធន៍បានបង្ហាញថា ក្រៅពីប្រើថ្នាំនុយ Mollucide6GB នៅមានថ្នាំមួយប្រភេទទៀតគឺ Osbuvang5G ដែលមានប្រសិទ្ធភាពដូចថ្នាំ Mollucide6GB ផងដែរ។ ការប្រើថ្នាំទាំងពីរប្រភេទនេះតាមកម្រិតណែនាំ គឺ១០គ.ក្រ Mollucide6GB (ប្រហែល១សែនរៀល) ឬ៥គ.ក្រ Osbuvang5G (ប្រហែល៥ម៉ឺនរៀល) ក្នុងមួយហិកតាមិនបណ្តាលឲ្យងាប់ត្រី កំពិសនិងក្តាមនៅក្នុងស្រែឡើយ។ ថ្វីត្បិតតែការប្រើប្រាស់ថ្នាំ Osbuvang5G ចំណាយតិច តែកសិករត្រូវតែប្រើប្រាស់ថ្នាំនុយទាំងពីរប្រភេទនេះឆ្លាស់គ្នា ជៀសវាងការបន្សាំបានរបស់ខ្យង។ សូមកុំប្រើថ្នាំ Snailicide700wp ឲ្យសោះ ពីព្រោះវាពុលខ្លាំងដល់ត្រី កំពិស និងក្តាមនៅក្នុងស្រែ។




ក្រាហ្វិក៧. លទ្ធផលនៃថ្នាំសម្លាប់ខ្យងបីប្រភេទទៅលើខ្យង (Golden apple snail) និងត្រី កំពិស ក្តាម (Fish, shrimp and crab)

១៦. **វិធីសាស្ត្រកាត់បន្ថយមមាចត្នោត:** លទ្ធផលនៃពិសោធន៍២ឆ្នាំកន្លងមកនេះបានបញ្ជាក់ថា ការពន្លិចទឹកដំណាំស្រូវនៅដំណាក់កាលសំណាបទៅបែកគុម្ពឲ្យលិចពាក់កណ្តាលស្លឹកក្នុងរយៈពេលពី៦ ទៅ១០ថ្ងៃ ជាវិធានការដ៏ល្អ

មួយក្នុងការកាត់បន្ថយកូនញាស់របស់មមាចត្នោត និងអត្រារស់របស់វា។ ក្នុងករណីនេះ អត្រាកូនញាស់បានធ្លាក់ចុះដល់៥៨% (៦ថ្ងៃ) ២០% (១០ថ្ងៃ) និង១៨% (១៤ថ្ងៃ) ដែលជាមធ្យមថយចុះ៥,៥%ក្នុងមួយថ្ងៃ ហើយភាគរយកូនញាស់ដែលនៅរស់ បន្ទាប់ពីបង្ខះទឹកបាន៦ថ្ងៃ ធ្លាក់ចុះដល់៤២% (៦ថ្ងៃ) ៣៣% (១០ថ្ងៃ) និង២៥% (១៤ថ្ងៃ) ដែលជាមធ្យមថយចុះ២,៩% ក្នុងមួយថ្ងៃ។




ក្រាហ្វិក៨. ភាគរយកូនមមាចត្នោតញាស់ (អ័ក្ស Y, Hatching) បន្ទាប់ពន្លិចទឹកពី២ ទៅ១៤ថ្ងៃ (អ័ក្ស X, day) និងភាគរយកូនមមាចត្នោតដែលញាស់ ហើយនៅរស់បន្ទាប់ពីបង្ខះទឹករយៈពេល៦ថ្ងៃ (អ័ក្ស Y, Surviving)

**១៧. ការបង្កើនផលិតភាពស្រូវស្សារ:** ទិន្នផលស្រូវស្សារអាចកើនឡើងពីជិត៣តោន/ហិកតា ទៅដល់ជាង៤តោន/ហិកតា និងបង្កើនប្រាក់ចំណេញដុលបានទ្វេរដង នៅពេលដែលកសិករប្រើប្រាស់ពូជស្រូវដែលបានបញ្ចេញដោយក្រសួងឲ្យបានត្រឹមត្រូវតាមលក្ខខណ្ឌដាំដុះ គ្រាប់ពូជសុទ្ធល្អ និងគ្រប់គ្រងជីជាតិដីតាមកម្រិតណែនាំ។




ក្រាហ្វិក៩. ទិន្នផលមធ្យម និងប្រាក់ចំណេញដុលរបស់ការអនុវត្តតាមបង្ខុំបច្ចេកទេស និងការបញ្ចូលពូជស្រូវធៀបជាមួយការដាំដុះតាមទម្លាប់របស់កសិករ។

## ២.៤- ការអង្កេត

**១៨. ដំណាំដំឡូងមី:** ជាទូទៅ ផ្ទៃដីដាំដុះដំឡូងមីក្នុង១គ្រួសារនៅខេត្តប៉ៃលិនមានការថយចុះពី៤ហិកតាក្នុងឆ្នាំ២០១០ មក៣,៧ហិកតាក្នុងឆ្នាំ២០១៣ ហើយក៏ដូចគ្នាដែរចំពោះខេត្តកំពង់ចាមគឺថយពី១,៣៣ហិកតាក្នុងឆ្នាំ២០១០ មក១,២៨ហិកតាក្នុងឆ្នាំ២០១៣។ ទិន្នផលដំឡូងមីនៅខេត្តប៉ៃលិនក្នុងឆ្នាំ២០១៣ មានប្រមាណ២៩តោន/ហិកតា ថយចុះជាងឆ្នាំ២០១០ប្រមាណ១៥តោន/ហិកតា និងខេត្តកំពង់ចាមថយចុះប្រមាណ៥តោន/ហិកតា (ទិន្នផលឆ្នាំ២០១៣មានប្រមាណ២០តោន/ហិកតា)។ ផ្ទុយទៅវិញ តម្លៃដំឡូងស្រស់មានការកើនឡើងខ្លាំងនៅខេត្តប៉ៃលិនគឺពី

១៨៦រៀលក្នុងឆ្នាំ២០១០ ទៅ២៥០រៀល/គ.ក្រក្នុងឆ្នាំ២០១៣ ហើយខេត្តកំពង់ចាមមានការកើនឡើងតែបន្តិចគឺប្រមាណ៥០រៀល/គ.ក្រ (ឆ្នាំ២០១៣ ថ្លៃប្រមាណ៣០០រៀល/គ.ក្រ)។

**១៩. ការដាំដុះពូជស្រូវដែលបញ្ចេញដោយវិទ្យាស្ថាន:** លទ្ធផលនៃការអង្កេតលើកសិករចំនួន២.៤២២គ្រួសារនៅខេត្តចំនួន១២ (តាកែវ កំពង់ចាម កំពង់ស្ពឺ ពោធិ៍សាត់ បាត់ដំបង សៀមរាប ព្រៃវែង កំពង់ឆ្នាំង បន្ទាយមានជ័យ ស្វាយរៀង កំពង់ធំ និងកំពត) បានបង្ហាញថា ក្នុងឆ្នាំ២០១២–១៣កន្លងមក (១)កសិករដាំដុះពូជស្រូវដែលបញ្ចេញដោយវិទ្យាស្ថាន (ជាពិសេសពូជស្រូវ១០ពូជ) លើស្រែប្រាំង (DS=៩៦៩ហិកតា) ចំនួន២២% ស្រែដើមរដូវវស្សា (EWS=៤៣៩ហិកតា) ចំនួន២៥% និងស្រែវស្សា (WS=៣.៣៩០ហិកតា) ចំនួន៣៧% (២)ដោយឡែកចំពោះពូជស្រូវ ផ្ការំដួល (PRD) ត្រូវបានដាំដុះលើផ្ទៃដីស្រែកណ្តាលរបស់ខេត្តទាំង១២ (១,០៨លានហិកតា) ចំនួន៤១% និងពូជស្រូវ រាំងជ័យ (RC) ត្រូវបានដាំដុះលើស្រែក្រោម (០,៤៦លានហិកតា) ចំនួន៥២%។

**២០. ការប្រើប្រាស់ជីលើដំណាំស្រូវ:** លទ្ធផលនៃការអង្កេតនៅក្នុងខេត្តទាំង១២ខាងលើ ក៏បានបង្ហាញផងដែរថា (១)មានកសិករតែ១–២,៥%ប៉ុណ្ណោះដែលមិនប្រើប្រាស់ជីកសិកម្មគ្រប់ប្រភេទ (២)មានកសិករប្រមាណ០,៥%ដែលប្រើប្រាស់ជីសរីរាង្គសុទ្ធ (OF) លើស្រូវប្រាំង (Dry season) ដើមរដូវវស្សា (Early wet season) និងវស្សា (Wet season) (៣)កសិករដែលប្រើប្រាស់ជីគីមី (CF) សុទ្ធមាន៩៤,៥%លើស្រូវប្រាំង ៤៦,៩%លើស្រូវដើមរដូវវស្សា និង៧៣,៨%លើស្រូវវស្សា និង(៤)មានកសិករប្រើប្រាស់ជីគីមីលាយជាមួយជាសរីរាង្គ (OF+CF) ចំនួន ៤,៦%លើស្រូវប្រាំង ៥២%លើស្រូវដើមរដូវវស្សា និង១៩,៣%លើស្រូវវស្សា។




ក្រាហ្វិក១០. ការទទួលយកពូជស្រូវបញ្ចេញដោយវិទ្យាស្ថាន និងការប្រើប្រាស់ជីលើដំណាំស្រូវតាមក្សេត្របរិស្ថាន

## ២.៤- មន្ទីរពិសោធន៍

**២១. មន្ទីរពិសោធន៍ជីវបច្ចេកវិទ្យា:** បាន និងកំពុងអនុវត្ត Extract DNA របស់ស្រទ្បាយកូនបង្កាត់ចំនួន១០ប្រជាករ ដែលមានស្រទ្បាយសរុបចំនួន៥៧៥ស្រទ្បាយ ដើម្បីវិភាគរកវត្តមានសែន (Gene) ក្រអូបនៅក្នុងស្រទ្បាយនីមួយៗ។ ស្រទ្បាយចំនួន៤៣ក្នុងចំណោម៧០ស្រទ្បាយ ដែលបានវិភាគរួចត្រូវបានរកឃើញមានវត្តមានសែន (Gene) ក្រអូប (អូមូសីហ្គូត) ដែលនេះជាលទ្ធផលដ៏សុក្រិតមួយសម្រាប់បន្តការងារស្រាវជ្រាវនៅជំហានបន្ទាប់ទៀត។

**២២. មន្ទីរពិសោធន៍គុណភាពអង្ករ:** បានអនុវត្តលើការវិភាគគុណភាពអង្ករលើលក្ខណៈរូបសាស្ត្រដោយប្រើម៉ាស៊ីន S21 អាមីឡូសធាតុ សីតុណ្ហភាពចម្អិន និង Gel consistency សរុបបានចំនួន១៩៩សំណាក។

**២៣. មន្ទីរពិសោធន៍ជាលិកាវប្បកម្មដំណាំ:** បានបន្តការដាំពង្រីក និងអភិរក្សពូជដំណាំតាមការធ្វើជាលិកាវប្បកម្មទៅលើដំណាំចំនួន៧ប្រភេទ ដែលក្នុងនោះមានដំណាំចេកចំនួន៥០សំណាក ដំឡូងឈើចំនួន៤ពូជ ដំឡូងផ្វាចំនួន៣ស្រទ្បាយ ដំឡូងបារាំងចំនួន៤ស្រទ្បាយ អំពៅ៥សំណាក ដើមដំបងយក្សចំនួន១សំណាក និងផ្កាចំនួន៦ពូជ សរុបចំនួន៧៣ពូជ/ស្រទ្បាយដំណាំ។

៣២. **តាមរយៈការចូលរួមជាវាគ្មិនក្នុងកម្មវិធីវិទ្យុ និងទូរទស្សន៍:** បានទទួលសម្ភាសន៍ និងថតជាខ្សែវីដេអូខ្លីជាមួយស្ថានីយ៍ទូរទស្សន៍ NHK របស់ប្រទេសជប៉ុន ចំនួន១លើក ដែលទាក់ទងនឹងស្ថានភាពទូទៅនៃផលិតកម្មដំណាំស្រូវនៅក្នុងប្រទេសកម្ពុជា និងកិច្ចអន្តរាគមន៍មួយចំនួនរបស់វិទ្យាស្ថាន ដើម្បីចូលរួមក្នុងការជំរុញឲ្យសម្រេចបាននូវផែនការនាំចេញអង្ករឲ្យបាន១លានតោននៅក្នុងឆ្នាំ២០១៥ ដោយផ្តោតជាពិសេសលើការអភិវឌ្ឍន៍វិស័យផលិតកម្មគ្រាប់ពូជសុទ្ធ និងបានចូលរួមជាវាគ្មិនក្នុងកម្មវិធីវេទិកាស្វែងយល់ពីកសិកម្មលើប្រធានបទវិធានការស្តារឡើងវិញក្រោយគ្រោះទឹកជំនន់ និងរាំងស្ងួត នៅស្ថានីយ៍ទូរទស្សន៍ជាតិកម្ពុជា ចំនួន១លើក។

៣៣. ថ្នាក់ដឹកនាំការិយាល័យចំនួន២រូប បានចូលរួមបង្រៀនថ្នាក់បរិញ្ញាបត្រនៅសាកលវិទ្យាល័យភូមិន្ទកសិកម្ម។

៣៤. **តាមរយៈសារណា:** បានដឹកនាំនិស្សិតថ្នាក់បរិញ្ញាបត្របានចំនួន២៧នាក់ និងថ្នាក់បណ្ឌិតបានចំនួន១នាក់ ដែលក្នុងនោះថ្នាក់បរិញ្ញាបត្រចំនួន ២២នាក់មកពីសាកលវិទ្យាល័យភូមិន្ទកសិកម្ម ៤នាក់មកពីសាលាជាតិកសិកម្មព្រែកលៀប ១នាក់មកពីសាកលវិទ្យាល័យជាស៊ីមកំចាយមារ និងថ្នាក់បណ្ឌិតចំនួន១នាក់មកពីរាជបណ្ឌិតសភាកម្ពុជា។

៣៥. **ការងារបណ្តុះបណ្តាល:** បានបើកវគ្គបណ្តុះបណ្តាល សិក្ខាសាលា និងសន្និបាតចំនួន២១លើក ដែលមានអ្នកចូលរួមសរុបចំនួន៧៨១នាក់។ បានចូលរួមវគ្គបណ្តុះបណ្តាល សិក្ខាសាលា និងសន្និបាតក្នុងប្រទេសចំនួន១៥លើក ដែលមានមន្ត្រីវិទ្យាស្ថានទៅចូលរួមសរុបចំនួន៣៣នាក់ និងក្រៅប្រទេសចំនួន៤១លើក ដែលមានថ្នាក់ដឹកនាំ និងមន្ត្រីវិទ្យាស្ថានចូលរួមចំនួន៥៤នាក់។ មន្ត្រី និយោជិតសរុបចំនួន៣រូបបានសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ និងថ្នាក់បណ្ឌិតនៅក្រៅប្រទេស។

៣៦. **ការងារសហប្រតិបត្តិការ:** បានធ្វើកិច្ចសហប្រតិបត្តិការជាមួយ IRRI, JIRCAS, Tokyo University, YAAS, AQIP Seed Co., Ltd., USAID/HARVEST/FINTRAC, IFC, FASMEC, CASS និង NIAS បានល្អខ្ជាប់ខ្ជួន។

## ៣- ទិសដៅឆ្នាំ២០១៥

### ៣.១. ការងារពិសោធន៍ស្រាវជ្រាវ និងបោះពុម្ពផ្សាយ

- បន្តការងារពិសោធន៍ស្រាវជ្រាវតាមរាជធានី-ខេត្ត និងនៅក្នុងវិទ្យាស្ថាន
- បន្តបញ្ចូលទិន្នន័យពិសោធន៍ឆ្នាំ២០១៤ ព្រមទាំងបញ្ចូលទិន្នន័យ និងធ្វើការវិភាគជាបណ្តើរៗរាល់ពិសោធន៍ ដែលចប់សព្វគ្រប់
- បន្តអភិរក្សពូជស្រូវ ចេក និងដំណាំផ្សេងៗនៅក្នុងវិទ្យាស្ថាន
- បន្តរៀបចំពិធីសារ និងសម្ភារសម្រាប់ពិសោធន៍ឆ្នាំ២០១៥
- បន្តធ្វើបរិសុទ្ធកម្មពូជស្រូវ ដែលបានបញ្ចេញដើម្បីឲ្យកាន់តែមានភាពធន់ទ្រាំទៅនឹងភាពរាំងស្ងួត ទឹកជំនន់ កត្តាចង្រៃ និងជំងឺនឹងបន្តការអភិរក្សពូជស្រូវធន់ជាតិប្រៃ និងពូជស្រូវវារដែលមានលទ្ធភាពវារឡើងតាមទឹកខ្លាំង
- បន្តអភិវឌ្ឍពូជស្រូវ និងដំណាំចម្ការឲ្យមានអាយុកាលខ្លីនិងធន់ទៅនឹងកំដៅ
- បន្តការស្រាវជ្រាវលើការគ្រប់គ្រងជីជាតិដី និងដំណាំ
- បន្តការស្រាវជ្រាវលើបច្ចេកទេសមុន និងក្រោយការប្រមូលផល ព្រមទាំងវិធានការណ៍គ្រប់គ្រងកត្តាចង្រៃ
- អភិវឌ្ឍយុទ្ធសាស្ត្របន្សុាំទៅនឹងការប្រែប្រួលអាកាសធាតុ
- បន្តរៀបចំ និងបោះពុម្ពអត្ថបទព័ត៌មាន ព្រឹត្តិបត្រស្រាវជ្រាវនិងទស្សនាវដ្តីកសិកម្មកម្ពុជារបស់វិទ្យាស្ថាន។

### ៣.២. ការងារគ្រប់គ្រងរដ្ឋបាល ផែនការ និងហិរញ្ញវត្ថុ

- រៀបចំហេដ្ឋារចនាសម្ព័ន្ធ ថែទាំនិងសម្អាតសួនច្បារដើម្បីកែលម្អសោភ័ណភាពក្នុងវិទ្យាស្ថានឲ្យបានល្អ
- អនុវត្តការងារភ្ជួរដាស់ដីក្រោយពីច្រូតកាត់រួចដើម្បីត្រៀមធ្វើពិសោធន៍រដូវវស្សាខាងមុខនេះ

- រៀបចំនិងអភិវឌ្ឍន៍នូវផែនការថវិកាសម្រាប់ឆ្នាំ២០១៥ សម្រាប់ស្នើសុំទៅរាជរដ្ឋាភិបាល
- ជំរុញបន្ថែមទៀតនូវការទំនាក់ទំនងជាមួយអង្គការស្ថាប័នជាតិ និងអន្តរជាតិដើម្បីជួយឲ្យវិទ្យាស្ថាន សម្រេចបាននូវគោលដៅរបស់ខ្លួន
- ពង្រឹងការងារគ្រប់គ្រងធនធានមនុស្សដែលបានអភិវឌ្ឍ និងជ្រើសតាំងដែលមានស្រាប់ក្នុងការិយាល័យ មជ្ឈមណ្ឌល
- ធ្វើការសហការជាមួយអាជ្ញាធរដែនដី ដើម្បីចូលរួមចំណែកអនុវត្តនូវកិច្ចអភិវឌ្ឍន៍នៅស្ថានីយ៍ស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកោះកេរ្តិ៍ខេត្តព្រះវិហារ
- បន្តព្យាយាមធ្វើទំនាក់ទំនងជាមួយផ្សារទំនើបនានានៅរាជធានីភ្នំពេញ ក្នុងការលក់អង្ករក្រអូបទាំងពីរប្រភេទបន្ថែមទៀតដើម្បីបង្កើនការផ្សព្វផ្សាយឲ្យទទួលបាននូវការចាប់អារម្មណ៍ពីមហាជន អំពីសមិទ្ធផលរបស់វិទ្យាស្ថាន
- បន្តចូលរួមអនុវត្តន៍សកម្មភាពនានាតាមការចាត់តាំង ឬចាត់អញ្ជើញពីថ្នាក់ដឹកនាំក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

## ៨- ការលំបាក

- កង្វះខាតមន្ត្រីស្រាវជ្រាវ និងមន្ត្រីជំនាញតាមរយៈការបាត់បង់បុគ្គលិកវិទ្យាស្ថានដោយសារមានទីផ្សារពលកម្មបញ្ញាពីគម្រោង និងអង្គការអភិវឌ្ឍន៍នានាមានកម្រិតខ្ពស់
- ចរន្តអគ្គិសនីដែលអគ្គិសនីខណ្ឌដង្កោផ្គត់ផ្គង់នៅដាច់ជាញឹកញាប់ជារៀងរាល់ថ្ងៃ បណ្តាលឲ្យខូចខាតនូវឧបករណ៍ និងសារធាតុវិភាគក្នុងមន្ទីរពិសោធន៍ព្រមទាំងសម្ភារៈអេឡិចត្រូនិចដែលធ្វើឲ្យមានការកើនឡើងនូវតម្រូវការប្រេងឥន្ធនៈសម្រាប់ម៉ាស៊ីនភ្លើង ហើយដោយខ្សែបណ្តាញប្រព័ន្ធទឹកស្អាតនៅមិនទាន់មកដល់វិទ្យាស្ថានផងដែរ
- ហេដ្ឋារចនាសម្ព័ន្ធសម្រាប់ការងារស្រាវជ្រាវនៅមានកម្រិតជាពិសេសមន្ទីរពិសោធន៍ដែលមានសមត្ថភាពស្រាវជ្រាវជាលក្ខណៈវិទ្យាសាស្ត្រ
- រថយន្ត និងគ្រឿងយន្តកសិកម្មសម្រាប់បម្រើឲ្យការងារស្រាវជ្រាវមានសភាពទ្រុឌទ្រោមដោយសារប្រើប្រាស់រយៈពេលយូរឆ្នាំជ្រុល។

## ៨- សំណូមពរ

វិទ្យាស្ថានមានតម្រូវការមួយចំនួនដូចជា:

- ត្រាក់ទ័រ ផាលនាស់ ម៉ាស៊ីនស្ទូង និងម៉ាស៊ីនច្រូតកាត់បោកបែន (Combine harvester)
- មន្ត្រីក្របខណ្ឌដែលមានជំនាញស្រាវជ្រាវ ជាពិសេសនិស្សិតដែលទើបនឹងចប់ការសិក្សា និងប្រលងជាប់ក្របខណ្ឌរដ្ឋ។

នាយកវិទ្យាស្ថាន